**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ០០៦.......សហវ.សារាចរ

**សារាចរ**

**ស្តីពី**

**ការបង់ភាគទានចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

អនុលោមតាមការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ២៥ សសរ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីការបង់ភាគទានរបស់ក្រសួង ស្ថាប័នចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ម.ហ.ស.**) ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ថវិកា ២០% នៃចំណែកប្រាក់រង្វាន់របស់ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ១០% នៃចំណែកប្រាក់រង្វាន់របស់ក្រសួង ស្ថាប័ន លើការប្រមូលចំណូលពីសេវាសាធារណៈ និងពិន័យ សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងគោលដៅធានាការបង់ចំណូលក្នុងអត្រា ២០% នៃចំណែកប្រាក់រង្វាន់របស់ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ១០% នៃចំណែកប្រាក់រង្វាន់របស់ក្រសួង ស្ថាប័ន លើការប្រមូលចំណូលពីសេវាសាធារណៈ និងពិន័យ ចូលក្នុង **ម.ហ.ស.** ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចដាក់ចេញនូវនីតិវិធីនៃការបង់ចំណូលនេះ ដូចតទៅ៖

**ក. វិសាលភាព**

ចំណែកប្រាក់រង្វាន់របស់ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ប្រើជាមូលដ្ឋានក្នុងការគណនាចំនួនទឹកប្រាក់បង់ភាគទានចូលក្នុង **ម.ហ.ស.** សំដៅត្រឹមកញ្ចប់ប្រាក់រង្វាន់សរុបរបស់ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ចំណែកប្រាក់រង្វាន់របស់ក្រសួង ស្ថាប័ន សម្រាប់ប្រើជាមូលដ្ឋានក្នុងការគណនាចំនួនទឹកប្រាក់បង់ភាគទានចូលក្នុង **ម.ហ.ស.** សំដៅត្រឹមចំណែកប្រាក់រង្វាន់របស់រដ្ឋបាលកណ្តាលក្រសួង ស្ថាប័ន ដែលទទួលបានពីការប្រមូលចំណូលពីសេវាសាធារណៈ និងពិន័យ ដែលកំណត់ដោយប្រកាសរួម ឬ ប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នសាមី។

**ខ. ការបង់ថវិកាភាគទានចូលក្នុង ម.ហ.ស.**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នប្រមូលចំណូលដែលស្ថិតនៅក្នុងវិសាលភាពនៃចំណុច "**ក**" ខាងលើ ត្រូវបង់ថវិកាភាគទានចូលក្នុង **ម.ហ.ស.** ជាប្រចាំខែ ដោយអនុវត្តគិតចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ តទៅ តាមវិធានដូចខាងក្រោម៖



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

**ខ.១. ការបង់ថវិកាភាគទាន ២០% នៃចំណែកប្រាក់រង្វាន់របស់ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- ផ្អែកលើចំណូលប្រមូលបានប្រចាំខែ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវធ្វើតារាងគណនាប្រាក់រង្វាន់ប្រចាំខែ ដូចមានក្នុង**ឧបសម្ព័ន្ធ "ក"** ដើម្បីគណនារកចំណែកថវិកា ២០% ដែលត្រូវបង់ចូលក្នុង **ម.ហ.ស.**
- អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវញែកកញ្ចប់ប្រាក់រង្វាន់របស់ទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងអត្រា ២០% ហើយបង់ចូលក្នុងគណនី **ម.ហ.ស.** ដែលគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវ ដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **(អ.គ.ហ.) ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់** ដូចខាងក្រោម÷

  - ឈ្មោះធនាគារ ÷ ធនាគារជាតិនៃកម្ពុជា
  - ឈ្មោះគណនី ÷ មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
  - លេខគណនីប្រាក់រៀល ÷ ០០០០០០០១៨៥៨៧។

**ខ.២. ការបង់ថវិកាភាគទាន ១០% នៃចំណែកប្រាក់រង្វាន់របស់ក្រសួង ស្ថាប័ន**

- ផ្អែកលើចំណូលប្រមូលបានប្រចាំខែ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើតារាងគណនាប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែ ដូចមានក្នុង**ឧបសម្ព័ន្ធ "ខ"** ដើម្បីគណនារកចំណែកថវិកា ១០% ដែលត្រូវបង់ចូលក្នុង **ម.ហ.ស.**
- ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង់ថវិកា ១០% នៃចំណែកប្រាក់រង្វាន់របស់ខ្លួន ចូលក្នុងគណនីរង្វាន់លើកទឹកចិត្ត ១% ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់** ដូចខាងក្រោម÷

  - ឈ្មោះធនាគារ ÷ ធនាគារជាតិនៃកម្ពុជា
  - ឈ្មោះគណនី ÷ រង្វាន់លើកទឹកចិត្ត ១%
  - លេខគណនីប្រាក់រៀល ÷ ០០០០០០០១៣៦៧១
  - លេខគណនីប្រាក់ដុល្លារអាមេរិក ÷ ០០០០០០០១៣៦៧២
- អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធត្រូវផ្ទេរថវិកា ១០% សរុប ដែលទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ចូលក្នុងគណនី **ម.ហ.ស.** ដែលគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវ ដោយ **អ.គ.ហ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់** ដូចខាងក្រោម÷

  - ឈ្មោះធនាគារ ÷ ធនាគារជាតិនៃកម្ពុជា
  - ឈ្មោះគណនី ÷ មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
  - លេខគណនីប្រាក់រៀល ÷ ០០០០០០០១៨៥៨៧។

**គ. ការបង្វែរថវិកា ១% នៃចំណូលមិនមែនសារពើពន្ធ**

ក្រសួង ស្ថាប័នពាក់ព័ន្ធដែលធ្លាប់បង់ថវិកា ១% នៃចំណូលមិនមែនសារពើពន្ធ ចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈគណនីរង្វាន់លើកទឹកចិត្ត ១% ដែលគ្រប់គ្រងដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កន្លងមក ត្រូវបង្វែរការបង់ថវិកា ១% នេះ ចូលក្នុងចំណែកថវិកាជាតិវិញ ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៣ តទៅ។

ទទួលបានសារាចរនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ[illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ